00375651

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/46

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 09 / 09
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA. Huy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"
# សាធារណៈ

## សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ
## ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ -ថ្ងៃជំនុំជម្រះទី ៤១

រៀបចំដោយ: សែ កុលវុឌ្ឍី និង Natacha WEXELS-RISER

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Crippa MATTEO, លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser, លោក លឹម ស៊ុយហុង |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង(ព្រឹក), លោក តាន់ សេណារ៉ុង(រសៀល) លោក Anees Ahmed, លោក Zachery Lampell, លោកស្រី ដុន សុលក្ខណ៍(ព្រឹក), កញ្ញា Lindsan Baruffa, កញ្ញា Welch Kirsty, លោក ជា ផល្លា(រសៀល) |

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

| |
|---|
| ជនជាប់ចោទ៖ លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក François Roux(អវត្តមាន), លោកស្រី Marie-Paule Canizares, លោកស្រី Heleyn Unac, លោក ចាន់ រ៉ាវុធ, កញ្ញា Lucile Nattiez |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ កញ្ញា Silke Studzinsky,លោក គង់ ពិសី, លោកស្រី Martin Jacquin, លោក គឹម ម៉េងឃី, កញ្ញា ទី ស្រីនណា, លោក Alain Werner , លោក ហុង គឹមសួន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖លោក Scott Bywater, លោកស្រី Maryvonne Maniacky, លោក ឡាយ ណារ៉ា, លោក ខែម លីនដារីតា |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖១០.៤៥ | បញ្ចប់ម៉ោង៖១១.០៥ |
| សម្រាក | ចាប់ផ្តើមម៉ោង៖១២.០០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| សម្រាកបន្ថែមពេលល្ងាច | ចាប់ផ្តើមម៉ោង៖ ១៥.៤៥ | បញ្ចប់ម៉ោង៖ ១៥.៥៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ៤០នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សំណើសុំធ្វើការបញ្ជាក់ទាក់ទងនឹងការកំណត់ពេលវេលាសម្រាប់ភាគីក្នុងការតាំងសំណួរទៅសាក្សី នៅសប្តាហ៍ក្រោយ និងសំណើសុំដាក់រូបថត ជិន ម៉េត នៅចំពោះមុខអង្គជំនុំជម្រះ | សហព្រះរាជអាជ្ញា | ៩.០៤ | ៩.៤០ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ជិន ម៉េត(E2/80) ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ និងស២៤ | អង្គជំនុំជម្រះ | ៩.៤១ | ១០.០៣ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ជិន ម៉េត(E2/80) ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ និងស២៤ | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ | ១០.០៥ | ១០.៥៥ |
| សំណើសុំពេលវេលាបន្ថែមសម្រាប់ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ | ១១.០៦ | ១១.០៨ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ជិន ម៉េត(E2/80) ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ និងស២៤ | មេធាវីការពារក្តី | ១១.០៩ | ១១.២៥ |
| ការកត់សម្គាល់បឋមទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន (E2/32) និងការពិភាក្សាដេញដោល | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ | ១១.២៩ | ១១.៣៩ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន(E2/32) ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ រួមបញ្ចូលទាំងជើងឯក | អង្គជំនុំជម្រះ | ១១.៤២ | ១៦.០០ |
| ការជូនដំណឹងអំពីការបែងចែកពេលវេលាសម្រាប់ភាគីក្នុងការតាំងសំណួរទៅសាក្សី | អង្គជំនុំជម្រះ | ១៣.៣០ | ១៣.៣៣ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការស្នើសុំធ្វើការបញ្ជាក់ទាក់ទងនឹងការកំណត់ពេលវេលាសម្រាប់ភាគីក្នុងការតាំងសំណួរទៅសាក្សីនៅសប្តាហ៍ក្រោយ និង សំណើសុំដាក់រូបថតរបស់ ជិន ម៉េត ចំពោះមុខអង្គជំនុំជម្រះ**

- សហព្រះរាជអាជ្ញាបានស្នើសុំឱ្យធ្វើការបញ្ជាក់ទៅលើការកំណត់ពេលវេលាសម្រាប់ភាគីក្នុងការតាំងសំណួរទៅសាក្សី KW-08, KW-09 ដែលនឹងត្រូវមកផ្តល់សក្ខីកម្មក្នុងម្នាក់សម្រាប់រយៈពេល ០២ ថ្ងៃ។ ពួកគេបានស្នើសុំរយៈពេល ១ ម៉ោង ៣០នាទី សម្រាប់សហព្រះរាជអាជ្ញានិងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងរយៈពេល ២ម៉ោង សម្រាប់[illegible]



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

ក្ដីក្នុងការសួរសំណួរទៅសាក្សីម្នាក់ៗ។ មេធាវីការពារក្ដីបានជំទាស់ចំពោះសំណើនេះ ហើយបានស្នើសុំថាមេធាវីការពារក្ដីត្រូវតែបានរយៈពេលស្មើនឹងពេលវេលារួមគ្នារបស់សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្ដឹង សម្រាប់ការសួរទៅសាក្សី។

- សហព្រះរាជអាជ្ញាក៏បានស្នើសុំឱ្យដាក់រូបថត ជិន ម៉េត ដែលបានបង្ហាញកាលពីម្សិលមិញ ដោយដើមបណ្ដឹងរដ្ឋប្បវេណីទៅក្នុងសំណុំរឿង និងនៅចំពោះមុខអង្គជំនុំជម្រះ។ មេធាវីការពារក្ដីបានកត់សម្គាល់ថា រូបថតរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានថតនៅមន្ទីរស២១ ប៉ុន្តែមិនជំទាស់ក្នុងការដាក់រូបថតនេះនៅចំពោះមុខអង្គជំនុំជម្រះនោះទេ។

**ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ជិន ម៉េត** (E2/80) **ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ និងស២៤ ដោយអង្គជំនុំជម្រះ**

- អង្គជំនុំជម្រះបានតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ជិន ម៉េត ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍ស២១ និងស២៤។

**ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ជិន ម៉េត** (E2/80) **ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍ ស២១ និងស២៤ ដោយភាគី**

- សហព្រះរាជអាជ្ញា ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី៣ និងមេធាវីការពារក្ដី បានតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ជិន ម៉េត ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍ស២១ និង ស២៤។

**ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ណាំ ម៉ុន** (E2/32) **ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍ស២១ រួមបញ្ចូលទាំងជើងឯក ដោយអង្គជំនុំជម្រះ**

- អង្គជំនុំជម្រះបានតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ណាំ ម៉ុន ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ រួមបញ្ចូលទាំងជើងឯក។

**ការជូនដំណឹងអំពីការកំណត់ពេលវេលាសម្រាប់ភាគី**

- អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីអំពីការកំណត់ពេលវេលាសម្រាប់ពួកគេ ក្នុងការតាំង

00375655



សំណួរទៅសាក្សី៖

១-សម្រាប់សាក្សីដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មសម្រាប់រយៈពេល១ថ្ងៃ៖ សហព្រះរាជអាជ្ញាមានរយៈពេល ៣០នាទី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមមានរយៈពេល ៤០នាទី និងមេធាវីការពារក្តីមានរយៈពេល ៤០នាទី។

២-សម្រាប់សាក្សីដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មសម្រាប់រយៈពេល០.៥ថ្ងៃ៖ សហព្រះរាជអាជ្ញាមានរយៈពេល ១៥នាទី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល ២០នាទី និងមេធាវីការពារក្តីមានរយៈពេល ២០នាទី។

៣-សម្រាប់សាក្សីដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មសម្រាប់រយៈពេល ១.៥ថ្ងៃ៖ សហព្រះរាជអាជ្ញាមានរយៈពេល ៤៥នាទី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល ៦០នាទី និង មេធាវីការពារក្តី មានរយៈពេល ៦០នាទី។

៤-សម្រាប់សាក្សីដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មសម្រាប់រយៈពេល ២ថ្ងៃ៖ សហព្រះរាជអាជ្ញាមានរយៈពេល ៦០នាទី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល ៨០នាទី និងមេធាវីការពារក្តី មានរយៈពេល ៨០នាទី។

**ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន** (E2/32) **ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរ ស២១ រួមបញ្ចូលទាំងជើងឯក ដោយអង្គជំនុំជម្រះ**

- អង្គជំនុំជម្រះបានបន្តតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ រួមបញ្ចូលទាំងជើងឯក។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣**

| លេខយោងរបស់អជសង | លេខយោងរបស់កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត សំងាត់ ឬសាធារណៈ) | កំណត់សម្គាល់ |
|---|---|---|---|---|
| E2/80.2 | គ្មាន | ឧបសម្ព័ន្ធ២៖លិខិតបញ្ជាក់របស់ ជិន ម៉េត | សាធារណៈ កោសលុប | 00281156-00281162<br>00286726-00286730<br>00322282-00322286<br>កោសលុបព័ត៌មាន |

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី- ០៩ កក្កដា ២០០៩ /សាធារណៈ

| | | | | |
|---|---|---|---|---|
| | | | | ខ្លួន |
| E3/16 | D45/1/8 | រូបភាពថតពីខាងលើអាកាសនៅគុកទួលស្លែង | សាធារណៈ | 00189137-00189137 មាននៅក្នុងE3រួចហើយ |
| E2/32.4 | គ្មាន | ឧបសម្ព័ន្ធ៤៖រូបថតឃៀតយ៉ុន យ៉ន យ៉ុន, ជួន យ៉ន,សុខ ហេង និង វ៉ាត ឃឿន | សាធារណៈ | 00274367-00274373 ជាពិសេស 00274367 ដល់ 00274369 |

| ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖ |
|---|
| បង្គាប់ឲ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកសវនាការវិញនៅថ្ងៃច័ន្ទ ទី១៣ ខែកក្កដា ឆ្នាំ២០០៩។ |

| ដីកាសម្រាប់ការលើកវារកាលសវនាការ |
|---|
| ការពន្យារពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃច័ន្ទ ទី១៣ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ៩.០០ ព្រឹក ។ |

ភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលទុន្ន Natacha WEXELS-RISER